# រឿង ភិក្ខុត្រូវខ្លាស៊ី



បានព្រឹថា ភិក្ខុ ៣០ រូប មួយក្រុមទៀត រៀនកម្មដ្ឋានក្នុងសម្នាក់របស់ព្រះមានព្រះភាគហើយ នៅចាំវស្សាក្នុងព្រៃ ធ្វើកតិកាគ្នាថា ម្នាលអ្នកមានអាយុ យើងគួរធ្វើសមណធម៌ រហូតអស់មួយយប់ក្នុងយាមទាំងបី យើងមិនគួរមកកាន់សម្នាក់នៃគ្នានឹងគ្នា ហើយក៏ទៅកាន់ទីផ្សេងៗ គ្នា ។ កាលភិក្ខុទាំងនោះធ្វើសមណធម៌ ក្នុងពេលជិតភ្លឺ ក៏សិងលក់ៗ មានខ្លាមួយក្បាលមកចាប់ភិក្ខុទៅស៊ី ម្តងមួយរូប ៗ ។ ភិក្ខុណា ៗ ក៏មិនបានបញ្ចេញសូម្បីវាចាថា ខ្លាចាប់ខ្ញុំហើយឡើយ ។ ភិក្ខុត្រូវខ្លាស៊ីរហូតអស់ ១៥ រូប ដោយអាការៈយ៉ាងនេះ ។ ដល់ថ្ងៃឧបោសថ ភិក្ខុដ៏សេសក៏សួរថា លោកផ្សេងទៀតនៅទីណា ក៏បានដឹងរឿងនោះហើយពោលថា បើត្រូវខ្លាចាប់ គប្បីប្រាប់ថា ឥឡូវនេះ ខ្ញុំត្រូវខ្លាចាប់ហើយ រួចក៏នាំគ្នានៅបន្តក្នុងព្រៃនោះទៀត ។ តមក ខ្លាក៏ចាប់ភិក្ខុកំលោះមួយរូប ដោយន័យមុន ។ ភិក្ខុកំលោះក៏ស្រែកថា ខ្លា លោកម្ចាស់ ។

ភិក្ខុទាំងឡាយក៏កាន់ឈើច្រត់ និងគប់ភ្លើងដេញតាម បំណងថា នឹងឲ្យវាព្រលែង ។ ខ្លាក៏ឡើងទៅកាន់ទីដាច់នៃភ្នំ ដែលភិក្ខុទាំងឡាយទៅមិនដល់ រួចផ្តើមស៊ីភិក្ខុនោះតាំងពីរជើង ។ ភិក្ខុទាំងឡាយក្រៅនោះ ក៏បានតែពោលថា នែសប្បុរស ឥឡូវនេះ កិច្ចដែលពួកយើងនឹងត្រូវធ្វើមិនមាន ដែល ឈ្មោះថាសេចក្តីវិសេសរបស់ភិក្ខុទាំងឡាយ រមែងប្រាកដក្នុងឋានៈ ដូច្នេះ ។ ភិក្ខុកំលោះនោះ ដេកនៅក្នុងមាត់ខ្លា គ្របសង្កត់ទុក្ខវេទនាដែលឈឺចុកចាប់ ហើយ

ចម្រើនវិបស្សនា ពេលខ្លាស៊ីដល់កជើង លោកបានសម្រេចជាព្រះសោតាបន្ន, ពេលខ្លាស៊ីទៅដល់ជង្គង់ បានសម្រេចជាព្រះសកទាគាមី, ពេលខ្លាស៊ីទៅដល់ផ្ចិត បានជាព្រះអនាគាមី, ពេលខ្លាស៊ីជិត ដល់បេះដូង ក៏សម្រេចព្រះអរហត្ត ព្រមដោយបដិសម្ភិទា ទើបថ្លែងឧទានដូច្នេះថា ៖

“សីលវា វតសម្បន្នោ, បញ្ញវា សុសមាហិតោ;
មុហុត្តំ បមាទមន្វាយ, ព្យគ្ឃេនោរុទ្ធមានសោ ។

បញ្ជរស្មឹ គហេត្វាន, សិលាយ ឧបរី កតោ;
កាមំ ខាទតុ មំ ព្យគ្ឃា, អដ្ឋិយា ច ន្ហារុស្ស ច;
កិលេសេ ខេបយិស្សាមិ, ផុសិស្សាមិ វិមុត្តិយំ” ។

យើងមានសីល ដល់ព្រមដោយវត្ត មានបញ្ញា មានចិត្តតាំងមាំល្អ ហើយ អាស្រ័យសេចក្តីប្រមាទមួយភ្លេត ទាំងដែលមានចិត្តមិនប្រទូស្តក្នុងខ្លាវាក៏ចាប់ទុកក្នុងក្រញាំក្រចក នាំទៅទុកលើដុំថ្ម ខ្លាស៊ីយើងដល់ឆ្អឹង និងសរសៃ ក៏ដោយ យើងនឹងធ្វើកិលេសឲ្យអស់ទៅ នឹងពាល់ត្រូវវិមុត្តិ ។

(សុមង្គលវិលាសិនី អដ្ឋកថា ទីឃនិកាយ មហាវគ្គ មហាសតិបដ្ឋានសុត្ត ឧទ្ទេសវារកថា)

ដោយសដវថ